# របាយការណ៍វឌ្ឍនភាព
# របស់រដ្ឋបាលសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ឆ្នាំ២០២០
# និងទិសដៅការងារបន្ត ឆ្នាំ២០២១

- ជាបឋមខ្ញុំព្រះករុណាខ្ញុំបាទ សូមក្រាបថ្វាយបង្គំ ព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះសង្ឃរាជ សម្តេចព្រះរាជាគណៈ និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ !
- សូមក្រាបថ្វាយបង្គំ ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!
- សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!
- សូមគោរពសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរពសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចធម្មវិសុទ្ធវង្សា** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរពសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង**លោកជំទាវ** ជាទីគោរពដ៏ខ្ពង់ខ្ពស់!
- សូមគោរពឯកឧត្តម **ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ជាទីគោរព!
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកសារព័ត៌មាន ដែលមានវត្តមានក្នុងថ្ងៃនេះ!
- សូមគោរពបងប្អូនជនរួមជាតិ ទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា !

ថ្ងៃនេះ ក្នុងនាមក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង និងក្នុងនាមរូបខ្ញុំផ្ទាល់ ខ្ញុំមានក្តីសោមនស្សរីករាយឥតឧបមា ដោយបានមកចូលរួមសន្និសីទសារព័ត៌មាន ស្តីពី "វឌ្ឍនភាពមូលដ្ឋាន ឃុំ សង្កាត់ និងទិសដៅបន្ត" ដែលបានរៀបចំឡើងដោយអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល នាក្នុងឱកាសនេះ ។

ជាបន្តទៅនេះខ្ញុំសូមការអនុញ្ញាតរាយការណ៍ដោយសង្ខេបអំពីស្ថានភាព និងវឌ្ឍនភាពមូលដ្ឋានសង្កាត់ស្ទឹងត្រែង យើងខ្ញុំដែលមានដូចតទៅៈ

## I-ស្ថានភាពទូទៅ នៃរដ្ឋបាលសង្កាត់ស្ទឹងត្រែង

សង្កាត់ស្ទឹងត្រែង គឺជាសង្កាត់មួយក្នុងចំណោមសង្កាត់ទាំងបួន ស្ថិតនៅក្នុងក្រុងស្ទឹងត្រែង

ខេត្តស្ទឹងត្រែង ។ សង្កាត់ស្ទឹងត្រែងមានភូមិចំនួន ០៥ ជាចំណុះ ដែលមានផ្ទៃដីសរុប **៧៨,៣២ គ.ម²** មានប្រជាពលរដ្ឋរស់នៅសរុប **៣.៦៨២** គ្រួសារ ស្មើនឹង **១៥.៤៦៥** នាក់ ស្រី **៧.៧៦០** នាក់។ ក្នុងនោះ អ្នកមានអាយុ ១៨ឆ្នាំឡើង ចំនួន **១២.២៥៣** នាក់ ស្រី **៦.០៨៨** នាក់ , អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតសរុបចំនួន **១០.០៦៤** នាក់ ស្រី **៤.៨២៤** នាក់។ ប្រភពទឹកសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់ និងបង្កបង្កើន ផលក្នុងសង្កាត់ទទួលបានពីទន្លេសេកុង និងទន្លេមេគង្គ។ សង្កាត់មានសមាជិកក្រុមប្រឹក្សាសរុប **១១** នាក់ ស្រី **០៣** នាក់ ។

## II-វឌ្ឍនភាព និងសមិទ្ធផលការងារដែលសម្រេចបានកន្លងមក

### ១-ផ្នែកសេដ្ឋកិច្ច

ឆ្នាំ២០២០ជាឆ្នាំទី៤ នៃអាណត្តិទី៤ របស់ក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង ដែលបានអនុវត្តការងារបម្រើមូលដ្ឋាន និងការអនុវត្តមុខងារជាភ្នាក់ងារប្រកបដោយប្រសិទ្ធិភាព និងស័ក្តិសិទ្ធិភាព ក្នុងន័យរួមចំណែកការអភិវឌ្ឍន៍នៅមូលដ្ឋានប្រកបដោយចិរភាព ។ ក្រុមប្រឹក្សាសង្កាត់ ដោយមានគណៈកម្មាធិការកសាងផែនការ និងថវិកាសង្កាត់ (គ.ផ.ថ) បានរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០១៨-២០២២) និងកម្មវិធីវិនិយោគសង្កាត់បីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ។ ដោយឡែកនៅឆ្នាំ២០២០នេះ ដោយមានថវិកាវិភាជន៍ពីរាជរដ្ឋាភិបាលសម្រាប់អភិវឌ្ឍន៍នៅមូលដ្ឋាន ក្រុមប្រឹក្សាសង្កាត់សម្រេចបានគម្រោងសាងសង់ផ្លូវបេតុងអាមេចំនួន **០៣ ខ្សែ** សរុបប្រវែង **៦៦៦ ម៉ែត្រ** ទទឹង **៥ ម៉ែត្រ** កម្រាស់ **១៥០ មម** ចំណាយថវិកាសរុបចំនួន **២១៧.៧៣០.០០០ រៀល** ជាគម្រោងអាទិភាពដែលឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋសម្រួលបាននូវការធ្វើដំណើរ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានបានយ៉ាងល្អប្រសើរ ។

ជាមួយគ្នានេះដែរនៅក្នុងឆ្នាំ២០២០ យើងពិនិត្យឃើញថា សង្កាត់ស្ទឹងត្រែង មានការរីកចម្រើនយ៉ាងខ្លាំងខាងវិស័យគមនាគមន៍។ ឈរលើមូលដ្ឋានសុខសន្តិភាព ក្រោមនយោបាយ ឈ្នះ ឈ្នះ និងយុទ្ធសាស្រ្តចតុកោណរបស់ប្រមុខរាជរដ្ឋាភិបាល និងការយកចិត្តទុកដាក់ពីរដ្ឋបាលខេត្ត-រដ្ឋបាលក្រុង កសាងបាននូវផ្លូវបេតុងសសៃដែក , ផ្លូវDBST , រៀបចំប្រព័ន្ធលូក្នុងក្រុង ក្នុងភូមិសាស្រ្តសង្កាត់ បានខ្វាត់ខ្វែងជាច្រើនខ្សែប្រកបដោយគុណភាព និងការពេញចិត្តពេញថ្លើមពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅក្នុងសង្កាត់ស្ទឹងត្រែងទាំងមូល ។ ព្រមទាំងបានកសាងច្រាំងទន្លេ រង្វង់មូល រូបសំណាក់ និងសំណង់អាគាររដ្ឋបាលប្រកបដោយសោភ័ណភាព និងសេចក្ដីថ្លៃថ្នូរ ។ល។

### ២-ផ្នែកសង្គមកិច្ច

នៅក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង បានបង្កើនការយកចិត្តទុកដាក់ និងកិច្ចសហការណ៍កាន់តែល្អប្រសើរជាមួយ មណ្ឌលសុខភាព និងមន្ទីរសុខាភិបាលខេត្ត ដើម្បីលើកកម្ពស់ផ្នែកសុខ

ភាពសហគមន៍ និងសុខុមាលភាពសង្គម ។ ស្ថិតក្នុងបរិបទនៃវិប្បត្តិកូវីដ-១៩ ក្រុមប្រឹក្សាសង្កាត់ ក៏បានចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋតាមភូមិ អំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩ និងការធ្វើចត្តាឡីស័ក ចំនួន ១៤ ថ្ងៃ ចំពោះពលករ ឬ អ្នកទើបត្រឡប់ពីក្រៅប្រទេស ដែលបានធ្វើតេស្ដិ៍កំហាករួចហើយ ។ ជាលទ្ធផលល្អក្នុងសង្កាត់ស្ទឹងត្រែង ក៏ដូចជាក្នុងខេត្តស្ទឹងត្រែង ទាំងមូលមិនមានករណីប្រជាពលរដ្ឋណាម្នាក់វិជ្ជមានវីរុសកូវីដ-១៩ នោះឡើយ ។

ក្នុងរយៈពេលនៃវិប្បត្តិកូវីដ-១៩ជាសកលនេះ ក្រុមប្រឹក្សាសង្កាត់ក៏បានយកចិត្តទុកដាក់អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល និងថ្នាក់ដឹកនាំ ខេត្ត-ក្រុង ព្រមទាំងអនុវត្តតាមកម្មវិធី ផ្ដល់សាច់ប្រាក់ជូនគ្រួសារក្រីក្រក្នុងអំឡុងពេល កូវីដ-១៩ ដែលមានដូចខាងក្រោម ៖

១-អនុវត្តកម្មវិធីរបស់រាជរដ្ឋាភិបាលក្នុងការឧបត្ថម្ភសាច់ប្រាក់ដល់ស្ដ្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ដែលមានប័ណ្ណសមធម៌បានចំនួន ៤៤ គ្រួសារ ។

២-ធ្វើការពិនិត្យផ្ទៀងផ្ទាត់គ្រួសារក្រីក្រប្រភេទ ១ និងប្រភេទ២ ដើម្បីអនុវត្តគោលនយោបាយផ្ដល់សាច់ប្រាក់តាមរយៈភ្នាក់ងារវីងចំនួន ១៧៨ គ្រួសារ ។

៣-បានចុះសម្ភាសន៍គ្រួសារក្រីក្រតាមការស្នើសុំក្នុងអំឡុងពេល កូវីដ-១៩ ចំនួន ១៣៥គ្រួសារ និងបានផ្ដល់ប័ណ្ណសមធម៌ដែលទទួលបានពីមន្ទីរផែនការខេត្ត ជូនដល់គ្រួសារក្រីក្រ និង ពិនិត្យផ្ទៀងផ្ទាត់ឱ្យពួកគាត់បើកប្រាក់ឧបត្ថម្ភតាមរយៈភ្នាក់ងារវីង ត្រឹមត្រូវតាមការណែនាំរបស់រាជរដ្ឋាភិបាល ។

### ៣-ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ក្រុមប្រឹក្សាសង្កាត់ បានចូលរួមព្រឹត្តិការណ៍នៃការរៀបចំពិធីបញ្ជ្រាបការយល់ដឹង និងការសម្អាតទន្លេក្រោមការដឹកនាំពីគណៈបញ្ជាការឯកភាពក្រុងស្ទឹងត្រែង ដើម្បីអបអរសាទរពិធីបុណ្យទន្លេលើកទី៦ ឆ្នាំ២០២០ ក្រោមប្រធានបទ «**ទន្លេសន្តិភាព ទន្លេនៃវិបុលភាព**» ។ និងបានចូលរួមកម្មវិធីផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពី ការសម្អាតក្រុង ដើម្បីអបអរសាទរទិវាជាតិទីក្រុងស្អាតលើកទី៨ ឆ្នាំ ២០២០ ក្រោមប្រធានបទ «**ទីក្រុងស្អាត ទីក្រុងដែលមានវិថីម្ហូបអាហារស្អាត**» ។

ក្នុងឆ្នាំ២០២០ ក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង និងប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ស្ទឹងត្រែង សូមសំដែងអំណរសាទរ ចំពោះចំណាត់ការរបស់រដ្ឋបាលក្រុង ដែលបានរៀបចំដោះដូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន ១៣៩ គ្រួសារ ដែលរស់នៅអាណាធិបតេយ្យ តាមមាត់ទន្លេសេកុងបានដោយជោគជ័យ ពិតជាបានលើកកម្ពស់សម្រស់ឆ្នេរទន្លេ និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈបានយ៉ាងល្អប្រសើរ ។ ជាពិសេសដោះស្រាយបានបញ្ហាការចោលសំរាមតាមទីសាធារណៈ និងបានរៀបចំឱ្យមានធុងសំរាមតាមសួនច្បារ ផ្សារ សាលារៀន និងតាមទីសាធារណៈនានា ។ តាមរយៈការរៀបចំព្រឹត្តិការណ៍ណែនាំ និងការផ្សព្វផ្សាយធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនធំបានកែប្រែឥរិយាបទ និងបានផ្លាស់ប្ដូរទំលាប់នៃការចោលសំរាម

ពាសវាលពាសកាល ។

ដើម្បីចូលរួមថែរក្សា និងគ្រប់គ្រងសម្បត្តិធនធានធម្មជាតិឱ្យបានគង់វង្ស រដ្ឋបាលខេត្តស្ទឹងត្រែង បានបង្កើតក្រុមការងារថ្នាក់ខេត្តដើម្បីចុះសិក្សា កំណត់ព្រំប្រទល់ បោះបង្គោលព្រំផ្ទៃបឹង និងចុះបញ្ជីទីតាំងបឹងប្រវត្តិសាស្ត្រចំនួន ០៥កន្លែង ស្ថិតក្នុងភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដែលមានទំហំ ២៦,២៦ ហិចតា រួមមាន ៖ បឹងផ្ទៀត , បឹងចោងហោង និងបឹងប្រិយ ។

### ៤-ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព បានអនុវត្តជាប្រចាំ តាមរយៈក្រុមប្រឹក្សាសង្កាត់ និងប៉ុស្តិ៍រដ្ឋបាលសង្កាត់ ។ រដ្ឋបាលសង្កាត់មានប្រជាការពារទាំង ០៥ ភូមិ សរុបចំនួន ៥០ នាក់ ដែលតែងតែបានចូលរួមយ៉ាងសកម្មជាមួយក្រុមប្រឹក្សាសង្កាត់ និងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ក្នុងការរួមចំណែករក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅមូលដ្ឋានភូមិនីមួយៗ ។ នៅឆ្នាំ២០២០កន្លងទៅនេះ ក្រុមប្រឹក្សាសង្កាត់ និងប៉ុស្តិ៍រដ្ឋបាលសង្កាត់បានចុះប្រជុំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ចំនួន ៥៤ លើក ដែលមានអ្នកចូលរួម សរុប ២.០៩៦ នាក់ ស្រី ១.២៨៨ នាក់ ។ និងបានធ្វើវេទិកាសាធារណៈជាមួយប្រជាពលរដ្ឋបានចំនួន ៤៩ លើក មានអ្នកចូលរួមសរុប ១.៩២២ នាក់ ស្រី ៩០៨ នាក់ ។

រដ្ឋបាលសង្កាត់បានអនុវត្តការផ្តល់សេវាតាមតម្រូវការ និងសេវាតាមសំណូមពរជូនដល់ប្រជាពលរដ្ឋប្រកបដោយស្មារតីទទួលខុសត្រូវ និងតម្លាភាព ។ ជាក់ស្តែងនៅក្នុងឆ្នាំ២០២០កន្លងទៅនេះ រដ្ឋបាលសង្កាត់បានចុះបញ្ជីអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-សំបុត្រកំណើត | បានចំនួន | ៣០២ នាក់ | ស្រី ១៥៨ នាក់ |
| ២-សំបុត្របញ្ជាក់កំណើត | បានចំនួន | ២៧១ នាក់ | ស្រី ១៣៤ នាក់ |
| ៣-សំបុត្រអាពាហ៍ពិពាហ៍ | បានចំនួន | ៣១៨ គូ | |
| ៤-សំបុត្រមរណភាព | បានចំនួន | ៧៤ នាក់ | ស្រី ៣២ នាក់ |

និងបានដាក់ចេញលិខិតរដ្ឋបាលចំនួន ២.៧៧៨ ច្បាប់ , ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៅថ្នាក់សង្កាត់សម្រេចបាន ០៩ ករណី និងបញ្ជូនទៅស្ថាប័នពាក់ព័ន្ធចំនួន ០៣ ករណី ។ និងបានសហការណ៍ជាមួយក្រុមការងារវាស់វែងដីធ្លីមានលក្ខណៈជាប្រព័ន្ធ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តស្ទឹងត្រែង បានវិនិច្ឆ័យបំពេញសលាបត្រក្បាលដីក្នុងសង្កាត់សម្រេចបានទាំង០៥ភូមិ ដែលមានក្បាលដីសរុបចំនួន ៩.៩៥៥ ក្បាលដី ។ និងបានកំណត់ព្រំប្រទល់ភូមិ ឃុំ បានជាក់លាក់ត្រឹមត្រូវស្របតាមការណែនាំរបស់ក្រសួងមហាផ្ទៃ ។

## III-ទិសដៅការងារបន្តរបស់រដ្ឋបាលសង្កាត់

នៅឆ្នាំ២០២១នេះ ក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង បានរៀបចំកម្មវិធីវិនិយោគសង្កាត់បីឆ្នាំរំកិល

(២០២១-២០២៣) ដោយប្រើប្រាស់ថវិកាវិភាជន៍ពីរាជរដ្ឋាភិបាល និងថវិកាគាំទ្រពីមន្ទីរវិស័យ និងអង្គភាពនានាតាមផ្នែកនីមួយៗ ដូចខាងក្រោម ៖

- គម្រោងសាងសង់ផ្លូវបេតុអាមេប្រវែង ៧៩០ ម៉ែត្រ ទទឹង ០៥ ម៉ែត្រ កម្រាស់ ១៥០ មម ស្ថិតនៅភូមិព្រែក សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង(ដោយប្រើប្រាស់ថវិកាមូលនិធិសង្កាត់ឆ្នាំ២០២១) ។

- បន្តការគាំទ្រ និងកិច្ចសហការណ៍ជាមួយភាគីពាក់ព័ន្ធដូចជាមណ្ឌលសុខភាព មន្ទីរសុខាភិបាល និងមន្ទីរវិស័យ/អង្គភាពជំនាញនានា ដើម្បីលើកកម្ពស់ផ្នែកសុខភាពសហគមន៍ និងសុខុមាលភាពសង្គម និងការផ្សព្វផ្សាយអប់រំណែនាំប្រជាពលរដ្ឋអំពីវិធានការណ៍បង្ការការចម្លងជំងឺកូវីដ-១៩ នៅក្នុងសហគមន៍ និងការធ្វើចត្តាឡីស័ក ១៤ ថ្ងៃ ។

-បន្តការចុះសម្ភាសន៍គ្រួសារក្រីក្រតាមការស្នើសុំ ក្នុងអំឡុងពេលកូវីដ-១៩ និងការប្រមូលទិន្នន័យជនពិការសម្រាប់ការកំណត់អត្តសញ្ញាណកម្មពិការភាពតាមគំរូសង្គម និងសិទ្ធិជាមូលដ្ឋាន ។

-បន្តការយកចិត្តទុកដាក់ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីអនាម័យ បរិស្ថាននិងការចូលរួមវេចខ្ចប់ការទុកដាក់សំរាមឱ្យមានរបៀប ។ បំផុសស្មារតីប្រជាពលរដ្ឋឱ្យចេះស្រឡាញ់បរិស្ថាន និងការចូលរួមថែរក្សាធនធានធម្មជាតិ ។

-បន្តការអនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព និងបន្តការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋតាមតម្រូវការ និងតាមសំណូមពរ ប្រកបដោយប្រសិទ្ធភាព ។ បន្តការយកចិត្តទុកដាក់ដោះស្រាយបញ្ហាប្រឈមនានានិង បញ្ហាទំនាស់ជូនប្រជាពលរដ្ឋក្រៅប្រព័ន្ធតុលាការ ។

-យកចិត្តទុកដាក់ចុះបញ្ជីអត្រានុកូលដ្ឋាន ជូនប្រជាពលរដ្ឋឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។ ពង្រឹងការចុះឈ្មោះស្នាក់នៅបណ្តោះអាសន្ន និង ជំរុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ , សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋដោយមិនគិតថ្លៃសេវា ។

-ដើម្បីបន្តការផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋឱ្យកាន់តែមានប្រសិទ្ធិភាព និងការអភិវឌ្ឍន៍គ្រប់ទីកន្លែងជូនប្រជាពលរដ្ឋស្របតាមគោលនយោបាយវិមជ្ឈការ ក្រុមប្រឹក្សាសង្កាត់ស្ទឹងត្រែង នឹងរៀបចំស្នើសុំបំបែកភូមិ ចំពោះភូមិណាដែលមានផ្ទៃដីធំ មានប្រជាពលរដ្ឋច្រើនពេក ពិបាកក្នុងការគ្រប់គ្រង និងក្តាប់ពីតម្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

## IV-**សេចក្តីសន្និដ្ឋាន**

ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាំងពីឆ្នាំ២០០២ បានផ្តល់សិទ្ធិអំណាច តួនាទី ភារកិច្ច និងការទទួលខុសត្រូវមកឱ្យ ឃុំ-សង្កាត់ ដើម្បី

ដឹកនាំ គ្រប់គ្រង និងការអភិវឌ្ឍន៍នៅមូលដ្ឋានរៀងៗខ្លួន ។ ធ្វើឱ្យឃុំ-សង្កាត់ មានលទ្ធភាព មានធនធានថវិកាអភិវឌ្ឍន៍នៅមូលដ្ឋានតាមតម្រូវការចាំបាច់ ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានយ៉ាងប្រសើរ ។ ដែលខុសពីការដឹកនាំមុនឆ្នាំ២០០២ ឃុំ-សង្កាត់ មិនដែលមានថវិកាសម្រាប់ការអភិវឌ្ឍន៍នៅមូលដ្ឋានរបស់ខ្លួនឡើយ ។

ក្នុងនាមក្រុមប្រឹក្សាសង្កាត់ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ សូមថ្លែងអំណរគុណចំពោះការដឹកនាំដ៏ឈ្លាសវៃ ភាពប៉ិនប្រសប់ ប្រកបដោយគតិបណ្ឌិតរបស់ប្រមុខរាជរដ្ឋាភិបាល ធ្វើឱ្យកម្ពុជាកាន់តែមានភាពរីកចម្រើនតាំងពីទីក្រុងដល់ជនបទ ធានាបានសន្តិសុខសណ្តាប់ធ្នាប់ និងសូមអរគុណសន្តិភាព ។

ជាទីបញ្ចប់ខ្ញុំសូមគោរពជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ ជោគជ័យគ្រប់ភារកិច្ច និងសមប្រកបតែនឹងពុទ្ធពរ និងពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពថ្លែងអំណរគុណ !